ក

មាតិកា

I.-ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

ព្រះរាជក្រឹត្យ

០៨-១១-២០១០-ព្រះរាជក្រឹត្យ នស/រកត/១១១០/៨៦០ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ ដល់លោក ហ្សូអែល អាល់ប៊ែរ និននាំងហ្គឺ (Joël, Albert Nininger) ជនជាតិបារាំង សញ្ជាតិបារាំង កើតនៅទីក្រុង AURILLAC (15) សាធារណរដ្ឋបារាំង ៩៦៤៥

២៣-១១-២០១(-ព្រះរាជក្រឹត្យ នស/រកត/១១១០/៨៩៦ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់លោក ចាង ជិនជុង (ZHANG ZHENZHONG) ជនជាតិចិន សញ្ជាតិចិន កើតនៅ ទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា ចាង តារា (ZHANG DARA) ៩៦៤៦

២៦-១១-២០១០-ព្រះរាជក្រឹត្យ នស/រកត/១១១០/៩០៤ ស្តីពី ការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី ម៉ៅ វិនជីន (MAO WENJUN) ជនជាតិចិន សញ្ជាតិចិន កើតនៅទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា ម៉ៅ រាជនី (MAO REACHNY) ៩៦៤៧

៣០-១១-២០១០-ព្រះរាជក្រឹត្យ នស/រកត/១១១០/៩០៨ ស្តីពី ការតែងតាំង ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា ចំនួន ០២ រូប មានឋានៈស្មើរដ្ឋលេខាធិការ បន្ថែមលើមុខងារបច្ចុប្បន្ន ៩៦៤៨

០១-១២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១២១០/៩១២ ស្តីពី ការតែងតាំង ឯកឧត្តម អ៊ាន លីសែ ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋលេខាធិការ ៩៦៤៩

០១-១២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១២១០/៩១៣ ស្តីពី ការតែងតាំង ឯកឧត្តមឧកញ៉ា សេង ឆាយអ៊ីវ ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈ ស្មើ រដ្ឋមន្ត្រី ៩៦៥០

០១-១២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១២១០/៩១៤ ស្តីពី ការតម្លើងឋានៈជូន ឯកឧត្តម នង សាវុធ ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈ ស្មើ រដ្ឋមន្ត្រី និង តែងតាំង ឯកឧត្តម ហួន ច័ន្ទរេតនា ជាជំនួយការសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ អគ្គនាយក ៩៦៥១

០៧-១២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១២១០/៩៣៥ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ចំពោះលោក សួន សុធី ៩៦៥២

០៧-១២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១២១០/៩៣៦ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ ចំពោះឯកឧត្តម សំ ផន ៩៦៥៣

០៩-១២-២០១០ -ព្រះរាជក្រឹត្យ នស/រកត/១២១០/៩៣៧ ស្តីពី ការដាក់អោយចូលនិវត្តន៍ នាយនគរបាលជាតិជាន់ខ្ពស់ ថ្នាក់ឧត្តមសេនីយ៍ ចំនួន ២៩ រូប នៃក្រសួងមហាផ្ទៃ ៩៦៥៤

II‑រាជរដ្ឋាភិបាល

១‑អនុក្រឹត្យ

១៧-១២-២០១០-អនុក្រឹត្យលេខ ១៥៨ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៩៦៥៦

២០-១២-២០១០-អនុក្រឹត្យលេខ ១៥៩ អនក្រ.បក ស្តីពី ការបង្កើតសញ្ញារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៩៦៥៨

២០-១២-២០១០-អនុក្រឹត្យលេខ ១៦០ អនក្រ.បក ស្តីពី ការផ្ទេរឥណទានថវិកា ៩៦៦២

១០-១២-២០១០ -អនុក្រឹត្យលេខ ១២០៨ អនក្រ.តត ស្តីពី ការ ជូនមេដាយស្ថាបនាជាតិ ៩៦៦៤

១០-១២-២០១០ -អនុក្រឹត្យលេខ ១២០៩ អនក្រ.តត ស្តីពី ការ ជូនមេដាយការងារ ៩៦៦៥

១០-១២-២០១០ -អនុក្រឹត្យលេខ ១២១០ អនក្រ.តត ស្តីពី ការ ជូនមេដាយសហមេត្រី ៩៦៦៨

១០-១២-២០១០ -អនុក្រឹត្យលេខ ១២១១ អនក្រ.តត ស្តីពី ការ ជូនមេដាយការងារ ៩៦៦៩

១០-១២-២០១០ -អនុក្រឹត្យលេខ ១២១២ អនក្រ.តត ស្តីពី ការ ជូនមេដាយស្ថាបនាជាតិ ៩៦៧០

១០-១២-២០១០ -អនុក្រឹត្យលេខ ១២១៣ អនក្រ.តត ស្តីពី ការ ជូនមេដាយស្ថាបនាជាតិ ៩៦៧១

១០-១២-២០១០ -អនុក្រឹត្យលេខ ១២១៤ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៩៦៧២

១០-១២-២០១០ -អនុក្រឹត្យលេខ ១២១៥ អនក្រ.តត ស្តីពី ការ ជូនមេដាយស្ថាបនាជាតិ ៩៦៧៣

១០-១២-២០១០ -អនុក្រឹត្យលេខ ១២១៦ អនក្រ.តត ស្តីពី ការ ជូនមេដាយមុនីសារាភ័ណ្ឌ ៩៦៧៥

១០-១២-២០១០ -អនុក្រឹត្យលេខ ១២១៧ អនក្រ.តត ស្តីពី ការ ជូនមេដាយសហមេត្រី ៩៦៧៦

១០-១២-២០១០ -អនុក្រឹត្យលេខ ១២១៨ អនក្រ.តត ស្តីពី ការ ជូនមេដាយសុវត្ថារា ៩៦៧៨

១០-១២-២០១០ -អនុក្រឹត្យលេខ ១២១៩ អនក្រ.តត ស្តីពី ការ ជូនមេដាយការងារ ៩៦៨០

១០-១២-២០១០ -អនុក្រឹត្យលេខ ១២២០ អនក្រ.តត ស្តីពី ការ ជូនមេដាយមុនីសារាភ័ណ្ឌ ៩៦៨៤

២‑សេចក្តីសម្រេច

១៦-១២-២០១០-សេចក្តីសម្រេចលេខ ៧១ សសរ ស្តីពី ការបន្ថែមសមាសភាព នៃគណៈកម្មការសម្រាប់ចាត់ចែងការសាងសង់អគារ សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ ខេត្តព្រៃវែង ៩៦៨៥

១៧-១២-២០១០-សេចក្តីសម្រេចលេខ ៧២ សសរ ស្តីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាសកម្មភាពជនពិការ ៩៦៨៧

III-ការិយាល័យកណ្តាលក្រសួង

ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

២៦-០២-២០១០ -លិខិតបញ្ជាក់លេខ ១០២២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ស្រី សុខខេង អ៊ីមផត អិចផត ៩៦៨៩

២៦-០២-២០១០ -លិខិតបញ្ជាក់លេខ ១០២៣ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ដេប៉េអា ត្មុមព្រៃ (កម្ពុជា) ៩៦៩១

២៦-០២-២០១០ -លិខិតបញ្ជាក់លេខ ១០៣២ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ហ្គោលដេន អប់តើធូនីធី ខមមើសល ៩៦៩៣

០១-៣-២០១០ -លិខិតបញ្ជាក់លេខ ១០៣៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ទីគី គ្រេដ ៩៦៩៥

០១-៣-២០១០ -លិខិតបញ្ជាក់លេខ ១០៣៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អង្គរ ហ្វ្រ៊ីន ផារ ៩៦៩៧

០១-៣-២០១០ -លិខិតបញ្ជាក់លេខ ១០៤៤ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខេប ស៊ុយធ្វើរធី លីមីធីត ៩៦៩៩

០១-៣-២០១០ -លិខិតបញ្ជាក់លេខ ១០៤៥ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន អង្គរ ទីឌីអេស ស៊ុយធ្វើរធី គីអិលស៊ី ៩៧០១

០១-៣-២០១០ -លិខិតបញ្ជាក់លេខ ១០៤៦ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ របស់ក្រុមហ៊ុន ក្រុមហ៊ុនផ្សារមូលបត្រ កម្ពុជា (ផ.ម.ក) ៩៧០៣

០១-៣-២០១០ -លិខិតបញ្ជាក់លេខ ១០៤៧ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខនតើស្ទេន ខបភើរេសិន ៩៧០៥

០១-៣-២០១០ -លិខិតបញ្ជាក់លេខ ១០៤៨ ពណ.ចបព ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និង ទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន ខេជីអេ ស៊ីទីស ៩៧០៧

ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៦០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ដល់លោក **ហ្សូអែល អាល់ប៊ែរ និននាំងជេ** (Joël, Albert Nininger) ជនជាតិបារាំង សញ្ជាតិបារាំង កើតថ្ងៃទី ១៩ ខែ មករា ឆ្នាំ ១៩៦៥ នៅទីក្រុង AURILLAC (15) សាធារណរដ្ឋបារាំង ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

ពរល. ១០១១. ៩៧៦

លេខ: ៧៧៧ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០១០

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩៩៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ញាតូបនីយកម្មដល់លោក **ចាង ជិនជុង** (ZHANG ZHENZHONG) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ២១ ខែ មករា ឆ្នាំ ១៩៨៧ នៅទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ចាង ដារា** (ZHANG DARA) ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

លេខ: ៨០០ ច.ល

[illegible] ចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១០

[illegible] រាជរដ្ឋាភិបាល

[illegible] ជិនកេន

ពរល. ១០១១. ៩១៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១០

ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩០៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្មដល់អ្នកស្រី **ម៉ៅ វិនជីន** (MAO WENJUN) ជនជាតិចិន សញ្ជាតិចិន កើតថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ១៩៦៣ នៅទីក្រុងសៀងហៃ សាធារណរដ្ឋប្រជាមានិតចិន ដោយប្តូរឈ្មោះជា **ម៉ៅ រាជនី** (MAO REACHNY) ។

មាត្រា ២ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រ.ល.១០១១.៩២០

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១០

លេខ:៧២៧ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ២០១០
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១១១០/៩០៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ចំនួន ០២ រូប មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **នូ សុខណ្ណារ៉ាំ**
២- ឯកឧត្តម **ញ៉ឹក ម៉ិនឈុម**

មាត្រា២ : សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រ.ល. ១០១១. ៩២៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១០

លេខ:៨៤៦ ច.ល
សំរាប់ចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៦២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្សតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងឯកឧត្តម អ៊ាន លីសែ ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

មាត្រា២ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រល. ១០១២. ៩៤៤

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១០

លេខ: ៨៣០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៧៣

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំងឯកឧត្តមឧកញ៉ា សេង នាយអ៊ិរ ជាទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើ រដ្ឋមន្ត្រី ។

មាត្រា២ : សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល. ១០១២. ៩២៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១០

លេខ: ៨៣៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០១០
[illegible]រាជរដ្ឋាភិបាល

[illegible]នកេន

ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៧៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី២ នៃព្រឹទ្ធសភា នាថ្ងៃទី ២០ ខែ មិនា ឆ្នាំ ២០០៦ ស្តីពីការជ្រើសតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : ក- តម្លើងឋានៈជូនឯកឧត្តម **នង សាខុន** ទីប្រឹក្សាសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **រដ្ឋមន្ត្រី** ។

ខ- តែងតាំងឯកឧត្តម **ហួន ចន្ទ័រតនា** ជាជំនួយការសម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **អគ្គនាយក** ។

មាត្រា២ : សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា និងសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ជករ

៣រល. ១០១៧.៩៣០

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១០

លេខ: ៨៣៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៣៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា

ចំពោះ

លោក សួន សុធី

មានគុណបំណាច់ និងស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រ៧. ១០១២.៩៥១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១០

លេខ: ៨៣៧ច.ល

ប្រតិចម្លងចែក

ភ្នំពេញ ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០១០

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចិនកេន

ព្រះរាជក្រឹត្យ

នស/រកត/១២១០/៩៣៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍

ចំពោះ

ឯកឧត្តម សំ ផន

សប្បុរសជន នៅរាជធានីភ្នំពេញ បានជួយកសាងសមិទ្ធផលនានា
នៅវត្តបាត្តលីវែន ឃុំសំពុងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

៣រ.ព. ១០១២. ៩៥២

នរោត្តម សីហមុនី

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១០

លេខៈ ៨៣៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០១០
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

ព្រះរាជក្រឹត្យ

នស / រកត / ១២១០ / ៩៣៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៩០៨ / ១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ /០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៥០១ / ១៧៨ ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៦១០ / ៤៦៤ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ២០១០ ស្តីពីការកែសម្រួលមាត្រា៣៥ នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានដាក់អោយចូលនិវត្តន៍នាយនគរបាលជាតិជាន់ខ្ពស់ថ្នាក់ឧត្តមសេនីយ៍ចំនួន ២៩ រូប នៃក្រសួងមហាផ្ទៃដូចមានរាយនាមខាងក្រោមៈ

១-	ឧត្តមសេនីយ៍ឯក	ហេង ហាក់	អត្តលេខ	០០៦៣
២-	ឧត្តមសេនីយ៍ឯក	សួរ ផន	អត្តលេខ	០០០៦
៣-	ឧត្តមសេនីយ៍ឯក	សុខ សារេត	អត្តលេខ	០១០៨
៤-	ឧត្តមសេនីយ៍ឯក	លន់ ណេត	អត្តលេខ	០០៥៤
៥-	ឧត្តមសេនីយ៍ឯក	ផន អ៊ីម	អត្តលេខ	០០៣២
៦-	ឧត្តមសេនីយ៍ឯក	ស៊ូ ធាន	អត្តលេខ	១៣៤១
៧-	ឧត្តមសេនីយ៍ទោ	យឹម ខេង	អត្តលេខ	០១៧០
៨-	ឧត្តមសេនីយ៍ទោ	សោភ័យ នុន	អត្តលេខ	០៤២៣
៩-	ឧត្តមសេនីយ៍ទោ	នួន ពិសី	អត្តលេខ	០៤៥៤

ROYAUME DU CAMBODGE
LE MINISTÈRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

១០-	ឧត្តមសេនីយ៍ទោ	**ឈុយ សាខុន**	អត្តលេខ	០០១៧
១១-	ឧត្តមសេនីយ៍ទោ	**គេន់ ខែន**	អត្តលេខ	០០៣៧
១២-	ឧត្តមសេនីយ៍ទោ	**ឡេវ ស៊ុនឆាំ**	អត្តលេខ	០១២៥
១៣-	ឧត្តមសេនីយ៍ទោ	**ជោត សំរ៉ាង**	អត្តលេខ	០៦៧៤
១៤-	ឧត្តមសេនីយ៍ត្រី	**អ៊ុំ សំផុន**	អត្តលេខ	០៥៩៥
១៥-	ឧត្តមសេនីយ៍ត្រី	**ហា មាន**	អត្តលេខ	០១៥៨
១៦-	ឧត្តមសេនីយ៍ត្រី	**ហេង សៀម**	អត្តលេខ	០៧១៤
១៧-	ឧត្តមសេនីយ៍ត្រី	**យន់ សន**	អត្តលេខ	០២៦២
១៨-	ឧត្តមសេនីយ៍ត្រី	**មោក ឈាង**	អត្តលេខ	០១៦០
១៩-	ឧត្តមសេនីយ៍ត្រី	**ហាម ច្រឹង**	អត្តលេខ	០៣៥៩
២០-	ឧត្តមសេនីយ៍ត្រី	**ខាំង សែត**	អត្តលេខ	០៣៧៧
២១-	ឧត្តមសេនីយ៍ត្រី	**អោម គឹមហេង**	អត្តលេខ	០១៥៩
២២-	ឧត្តមសេនីយ៍ត្រី	**សុះ ណាល់**	អត្តលេខ	០៣០១
២៣-	ឧត្តមសេនីយ៍ត្រី	**ហាច់ សាឃឿន**	អត្តលេខ	០៦២៩
២៤-	ឧត្តមសេនីយ៍ត្រី	**ជា សុវណ្ណ**	អត្តលេខ	១៣៩៤
២៥-	ឧត្តមសេនីយ៍ត្រី	**ជី ខែត**	អត្តលេខ	២២២៧
២៦-	ឧត្តមសេនីយ៍ត្រី	**សះ ប៊ុន**	អត្តលេខ	០២២២
២៧-	ឧត្តមសេនីយ៍ត្រី	**ស្រី សារឿន**	អត្តលេខ	០២៨៩
២៨-	ឧត្តមសេនីយ៍ត្រី	**និត សុន**	អត្តលេខ	០៦៤៨
២៩-	ឧត្តមសេនីយ៍ត្រី	**និត្យ សំអាន**	អត្តលេខ	០៧៤៦

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្ត អោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

៣រ៧. ១០១២. ៩៥៣

នរោត្តម សីហមុនី

លេខៈ៤៣១ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១០

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ២០១០

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥, ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤, ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨, ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦, ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៦, ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក, ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក, ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក, ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និងអនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២២៧ អនក្រ.បក, ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋ តាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១០
- បានឃើញប្រកាសលេខ ១២៦០ សហវ.ប្រក, ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបែងចែកឥណទានចំណាយថវិកាផ្ទៃក្នុងជំពូក តាមគណនី អនុគណនី សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- លិខិតលេខ ៤១៧៦ អយក.ហវ, ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាមិនមែនកម្មវិធី ចំនួន ១.៣៩៥លានរៀល ពី ផ្នែកយុវជន និង កីឡា នៃក្រសួងអប់រំ យុវជន និងកីឡា ក្នុងនោះ ជំពូក៦២ (សេវាខាងក្រៅផ្សេងៗ) ចំនួន ៧៧០លានរៀល និងជំពូក៦៥ (ឧបត្ថម្ភកធន និងជំនួយសង្គម) ចំនួន ៦២៥លានរៀល មកជាថវិកាមិនមែនកម្មវិធី ផ្នែកឧត្តមសិក្សា ជំពូក ៦១ ដើម្បីសម្រាប់ជួសជុលអគារ ដែលខូច ក្នុងឆ្នាំ ២០១០ ។

មាត្រា២ : ការបែងចែកឥណទានថវិកាផ្ទេរក្នុងជំពូកនេះ តាមគណនី និងអនុគណនី ត្រូវធ្វើឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការចំណាយជាក់ស្តែង របស់ក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

មាត្រា៣ :រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ខែ ៨ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ *ហ៊ុន សែន* នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៥៩ . អនក្រ . បក

អនុក្រឹត្យ

ស្តីពី

ការបង្កើតសញ្ញារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ/បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- យោងតាមការចាំបាច់

សម្រេច

មាត្រា១.-

ត្រូវបានបង្កើតសញ្ញារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ប្រើប្រាស់ជាផ្លូវការក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា២.-

សញ្ញារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដូចមាននៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចតទៅ ៖

- ទម្រង់ទូទៅជារាងមូល ស្រួចលើ និងស្រួចក្រោម
- ផ្នែកខាងក្រោមបំផុតនៃសញ្ញាមានរូបក្បាច់អង្គរទ្រសញ្ញាទាំងមូល។ ក្បាច់នេះបញ្ជាក់អំពីប្រជាជាតិមួយប្រកបដោយអរិយធម៌ដ៏រុងរឿង និងសម្បុរបែបដែលតំណាងឲ្យកម្លាំងចលករទ្រទ្រង់វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- រូបស្លឹកស្រូវព័ទ្ធពីខាងក្រៅជារាងស្នែងក្របី ដែលម្ខាងៗមានស្លឹកចំនួន៧ ដោយរួមទាំងស្លឹកសេសមួយនៅខាងលើបំផុត។ រូបស្លឹកស្រូវនេះ តំណាងឲ្យប្រជាពលរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ដែលទទួលសេវាពីស្ថាប័នរដ្ឋ លើផ្នែកការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ពាក់កណ្តាលរង្វង់ផ្នែកខាងលើមានអក្សរ "ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ" និងពាក់កណ្តាលរង្វង់ផ្នែកខាងក្រោមដែលខណ្ឌដោយក្បាច់ផ្កាចន្ទន៍តូចៗពីរ មានអក្សរអង់គ្លេស "Ministry of Labour and Vocational Training"។ អក្សរទាំងនេះ ពណ៌ខៀវ ជាឈ្មោះស្ថាប័ន
- រង្វង់ស្តីតំណាងឲ្យគំនិតច្នៃប្រឌិតរស់រវើក និងបង្កើតថ្មីលើការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងបង្កើតការងារដល់ប្រជាពលរដ្ឋគ្រប់ទិសទីប្រកបដោយចីរភាព
- រូបជើងពានពណ៌មាសទ្រសៀវភៅបើកដែលមានចារឹកអក្សរ **ករប** តំណាងឲ្យក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្សេនតម្រាវិជ្ជាសាស្ត្រ អប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ និងច្បាប់ស្តីពីការងារ ក៏ដូចជាលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន
- ពណ៌ផ្ទៃមេឃដែលប្រើក្នុងនិមិត្តសញ្ញានេះ តំណាងឲ្យវឌ្ឍនភាព និងសុខដុមរមនាក្នុងសង្គម។

មាត្រា៣.-

សញ្ញារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សម្រាប់ប្រើប្រាស់ ដូចខាងក្រោមនេះ ៖

- ដាក់នៅកន្លែងធ្វើការ
- ពាក់លើឯកសណ្ឋានមន្ត្រីរាជការក្នុងក្របខណ្ឌក្រសួង
- ដាក់លើក្បាលលិខិតជាផ្លូវការរបស់ក្រសួង
- ប្រើប្រាស់ជាផ្លូវការផ្សេងៗទៀត។

មាត្រា៤.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន អភិបាលនៃគណៈអភិបាលរាជធានី និងខេត្តទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តតាមអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៤
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ.....១៥៩.អនក្រ.បក.ចុះថ្ងៃទី..២០...ខែ....ធ្នូ.........ឆ្នាំ ២០១០
ស្តីពីការបង្កើតសញ្ញារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

Ministry of Labour and Vocational Training

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៦០ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការផ្ទេរឥណទានថវិកា

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ , ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម្យលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម្យលេខ នស/រកម/០៥០៨/០១៦ , ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រម្យលេខ នស/រកម/១២០៩/០២៦ , ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក , ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក , ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក , ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០៨ ស្តីពីការបំពេញបន្ថែម និង កែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក , ចុះថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និង រដ្ឋាករ នាយកដ្ឋានពន្ធដារ និង រតនាគារជាតិ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឲ្យទៅជាអគ្គនាយកដ្ឋានគយ និង រដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២២៨ អនក្រ.បក , ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីការបែងចែកចំណាយថវិកាទូទៅរបស់រដ្ឋតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១០
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

សម្រេច

មាត្រា១: ត្រូវបានអនុញ្ញាតឲ្យផ្ទេរឥណទានថវិកា ចំនួន ៣៨៣.៥២៥.០០០រៀល(បីរយប៉ែតសិបបីលានប្រាំរយម្ភៃប្រាំពាន់រៀលគត់) ពីជំពូក៦០ (ការទិញ) ចំនួន ២៧២.០០០.០០០រៀល(ពីររយចិតសិបពីរលានរៀលគត់) និង ជំពូក៦១ (សេវាខាងក្រៅ) ចំនួន ១១១.៥២៥.០០០រៀល(មួយរយដប់មួយលានប្រាំរយម្ភៃប្រាំពាន់រៀលគត់) មកជំពូក៦២ (សេវាខាងក្រៅផ្សេងៗ) ជូនក្រសួងមហាផ្ទៃ ផ្នែកសន្តិសុខសាធារណៈ សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១០ ។

មាត្រា២: ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះ តាមគណនី និង អនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្រាប់ទូទាត់សោហ៊ុយបេសកកម្ម និងស្នាក់នៅក្នុងប្រទេសឆ្នាំ ២០០៨ ២០០៩ និង២០១០ ។

មាត្រា៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

គាត ឈន់

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២០៨.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជន ចំនួន០៩រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន រួមចំណែកកសាងព្រះវិហារ វត្តខេមរាសាមគ្គីមុនីវង្ស ស្ថិតនៅក្នុងឃុំពួក ស្រុកពួក ខេត្តសៀមរាប ដូចមានរាយនាមខាងក្រោម ៖

១-ព្រះតេជគុណ	ណុប	ឡុន	ព្រះចៅអធិការ	វត្តខេមរាសាមគ្គីមុនីវង្ស
២-ឧបាសក	ប៊ុន	ប៊ុត	គណៈកម្មការ	វត្តខេមរាសាមគ្គីមុនីវង្ស
៣-ឧបាសក	ឡាច	ឡៃ	គណៈកម្មការ	វត្តខេមរាសាមគ្គីមុនីវង្ស
៤-ឧបាសក	ជួម	សុភាត់	អាចារ្យ	វត្តខេមរាសាមគ្គីមុនីវង្ស
៥-ឧបាសិកា	ទុំ	រ៉េម		
៦-ឧបាសិកា	សុខ	ជីវី		
៧-លោក	ម៉ៅ	សួម		
៨-អ្នកស្រី	ប៊ុន	រ៉េម		
៩-អ្នកស្រី	ភន	នី		

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស និងអភិបាលនៃគណៈអភិបាលខេត្តសៀមរាប ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១២៧០៩.អនក្រ.ក្រ

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន៥០រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចលើវិស័យអាកាសចរស៊ីវិល ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសការងារ

១-ឯកឧត្តម	ពុត	សុខា	អនុរដ្ឋលេខាធិការ
២-លោក	ឡុង	ណូ	អនុប្រធាននាយកដ្ឋានអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
៣-លោក	ញឹក	សារឹម	អធិការរង អធិការដ្ឋាន
៤-លោក	ម៉ី	សារុន	អនុប្រធាននាយកដ្ឋានផ្គត់ផ្គង់ហិរញ្ញវត្ថុ
៥-លោកស្រី	អ៊ុំ	សាភត	អនុប្រធានការិយាល័យអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
៦-លោក	សោម	សារ៉ាន	អនុប្រធានការិយាល័យសន្តិសុខ
៧-លោក	ថុង	និច	អនុប្រធាននាយកដ្ឋាន ផ្គត់ផ្គង់ហិរញ្ញវត្ថុ

ខ-មេដាយប្រាក់ការងារ

១-លោក	ស៊ីន	ប៊ុនថាត	អនុប្រធាននាយកដ្ឋាន ផ្គត់ផ្គង់ហិរញ្ញវត្ថុ
២-លោក	គីម	ចាន់ណារិទ្ធ	អនុប្រធាននាយកដ្ឋានប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ
៣-លោក	វីម	វិសាល	អនុប្រធាននាយកដ្ឋានប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ

៤-លោក	អ៊ុន	ទ៊ាន់ឆួន	អនុប្រធាននាយកដ្ឋាន អាកាសយានដ្ឋានអន្តរជាតិសៀមរាប
៥-លោក	អ៊ឹម	ថុល	អនុប្រធាននាយកដ្ឋាន អាកាសយានដ្ឋានអន្តរជាតិសៀមរាប
៦-លោក	ជា	សុខខេង	អនុប្រធាននាយកដ្ឋានប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ
៧-លោក	ស្រេង	ពៅ	អធិការរងអធិការដ្ឋាន
៨-លោក	ឆាយ	វណ្ណៈ	ប្រធានការិយាល័យ ផ្គត់ផ្គង់ហិរញ្ញវត្ថុ
៩-លោក	ម៉ិត	រ៉ាឌី	ប្រធានការិយាល័យដឹកជញ្ជូនផ្លូវអាកាស
១០-លោក	អួន	សំអាត	ប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិសៀមរាប
១១-លោក	ហេង	សុខា	ប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិសៀមរាប
១២-លោក	ម៉ី	កុសល	ប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
១៣-លោក	ព្រហ្ម	ឆួន	ប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិសៀមរាប
១៤-លោក	ឆាំ	ម៉ិនធឿន	ប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
១៥-លោក	ហាម	ហុន	ប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
១៦-លោក	ឥន្ទ	ចន្ទរិទ្ធ	ប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
១៧-លោក	ទ័រ	ចាន់ថន	ប្រធានការិយាល័យ វិស្វកម្មអេឡិចត្រូនិក
១៨-លោកស្រី	សួន	ស្រី	ប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
១៩-លោក	កៅ	ឃុន	អនុប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
២០-លោកស្រី	ឆៀង	ធារីកា	អនុប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
២១-លោក	លឹម	មន្ថា	អនុប្រធានការិយាល័យ ផ្គត់ផ្គង់ហិរញ្ញវត្ថុ
២២-លោកស្រី	អ៊ុក	សាឡូត	អនុប្រធានការិយាល័យ រដ្ឋបាល-បុគ្គលិក
២៣-លោកស្រី	ណែម	ចាន់	អនុប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
២៤-លោក	ឡុង	រដ្ឋា	អនុប្រធានការិយាល័យ ប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ
២៥-លោកស្រី	សុខ	ស៊ីហួន	អនុប្រធានការិយាល័យ ប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ
២៦-លោក	នៅ	ឈៃល	អនុប្រធានការិយាល័យ ផ្គត់ផ្គង់ហិរញ្ញវត្ថុ
២៧-លោកស្រី	ឌី	សា	លេខាធិការ ប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ

គ-មេដាយសេវាកម្មការងារ:

១-លោក	ញឹម	សុខា	ប្រធានការិយាល័យ ផ្គត់ផ្គង់ហិរញ្ញវត្ថុ
២-លោក	អេង	រ៉ា	ប្រធានការិយាល័យសន្តិសុខ
៣-លោក	ឃុន	ភាព	ប្រធានការិយាល័យ ដឹកជញ្ជូនផ្លូវអាកាស
៤-លោកស្រី	ផាន់	ស៊ីណាត	អនុប្រធានការិយាល័យ ប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ
៥-លោក	លឹន	ស៊ូម៉ារ៉ា	អនុប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
៦-លោក	សុខ	ពេជ្រវិជ្ជា	អនុប្រធានការិយាល័យ រដ្ឋបាល-បុគ្គលិក
៧-លោក	សុត្រ	សម្បត្តិ	អនុប្រធានការិយាល័យ ដឹកជញ្ជូនផ្លូវអាកាស
៨-លោក	អឿន	វណ្ណា	អនុប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
៩-លោក	សុខ	ពិសិដ្ឋ	អនុប្រធានការិយាល័យ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
១០-លោក	ម៉ែន	សុគន្ធ	មន្ត្រីគ្រប់គ្រងរដ្ឋបាល ផ្គត់ផ្គង់ហិរញ្ញវត្ថុ
១១-លោក	ម៉េង	ទី	មន្ត្រីគ្រប់គ្រងរដ្ឋបាលផែនការ នីតិកម្ម
១២-លោក	សុង	ហុង	មន្ត្រីគ្រប់គ្រងរដ្ឋបាល-បុគ្គលិក

១៣-លោក	សេង	ច័ន្ទពិសិដ្ឋ	មន្ត្រីគ្រប់គ្រងរដ្ឋបាល-បុគ្គលិក
១៤-លោក	ស៊ិន	សិទ្ធិ	មន្ត្រីគ្រប់គ្រងរដ្ឋបាល ផែនការ នីតិកម្ម
១៥-លោក	និន្ទ	និត្យសង្គ្រាម	មន្ត្រីក្រមការ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
១៦-លោក	គ្រូច	ទើត	លេខាធិការ ប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ
១៧-លោក	ឃឹម	ច័ន្ទនីតា	ភ្នាក់ងាររដ្ឋបាល សន្តិសុខ
១៨-លោក	ស្ងួស	សុផាត	ភ្នាក់ងាររដ្ឋបាល អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
១៩-លោក	ច័ត	អិន	ភ្នាក់ងាររដ្ឋបាល វិស្វកម្មអេឡិចត្រូនិក
២០-លោក	មុត	សីម	ភ្នាក់ងាររដ្ឋបាល រដ្ឋបាល-បុគ្គលិក
២១-លោក	ចាន់	ត្រូយ៉ាណា	ភ្នាក់ងាររដ្ឋបាលអាកាសយានដ្ឋានក្នុងស្រុក
២២-លោកស្រី	អ៊ុយ	ចាន់បុផ្ផា	ភ្នាក់ងាររដ្ឋបាល ប្រតិបត្តិការ និងសុវត្ថិភាពហោះហើរ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១២១០ .អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសមាមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងព័ត៌មាន

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយសមាមេត្រី តាមលំដាប់ថ្នាក់ ជូនគណៈប្រតិភូវិទ្យុសម្លេងវៀតណាម (VOV) នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចំនួន០៩រូប ដែលបានផ្តល់ម៉ាស៊ីនផ្សាយសម្លេងវិទ្យុ ចំនួន០៥សំរាប់ ០១សំរាប់ មានកំលាំង FM 5KW និង០៤សំរាប់ទៀត មានកំលាំង FM 2KW ព្រមទាំងបំពាក់សម្ភារៈគ្រប់គ្រាន់ ជូនក្រសួងព័ត៌មាន មានតម្លៃជាទឹកប្រាក់សរុបចំនួន ១.១៥៤.៨៧០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយសមាមេត្រី ថ្នាក់ ធិបឌិន្ទ:

១-លោក	ដាវ យ៉ូហ៊ឿ	(Dao Duy Hua)	អគ្គនាយករងវិទ្យុសម្លេងវៀតណាម
២-លោក	ដន់ វៀតជុង	(Doan Viet Trung)	អគ្គនាយករងវិទ្យុសម្លេងវៀតណាម
៣-លោកស្រី	ហ្វាង មិញង្វៀត	(Hoang Minh Nguyet)	អគ្គនាយករងស្តីទី វិទ្យុសម្លេងវៀតណាម
៤-លោក	ដូ	ង៉ុកដាង (Do Ngoc Dang)	ប្រធាននាយកដ្ឋានចាត់តាំងវិទ្យុសម្លេងវៀតណាម
៥-លោក	ង៉ូ	ស៊ន់ធី (Ngo Xuan Thi)	អគ្គនាយកនៃអគ្គក្រុមហ៊ុន អ៊ីម៉ិចកូ (EMI CO)

ខ-មេដាយសមាមេត្រី ថ្នាក់ សេនា:

១-លោក	ផាន ក្វាងជិញ	(Phan Quang Chinh)	អគ្គនាយករងនៃអគ្គក្រុមហ៊ុន អ៊ីម៉ិចកូ (EMI CO)
២-លោក	ង្វៀង ទៀនឡុង	(Nguyen Tien Long)	ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
៣-លោក	ង្វៀន វ៉ាន់ឃៀម	(Nguyen Van Khiem)	អនុប្រធានស្តីទី នៃ ន.សហប្រតិបត្តិការអន្តរជាតិ
៤-លោក	ដូ	វ៉ាន់ឡួន (Do Van Loan)	អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១០
នាយករដ្ឋមន្ត្រី
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១២១១ . អនក្រ . តប

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមាសការងារ ជូនមន្ត្រីរាជការ និងសប្បុរសជន ចំនួន០៤រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចព្រមទាំងបានចូលរួមកសាងសមិទ្ធផលនានា រួមចំណែកក្នុងការអភិវឌ្ឍខេត្តឧត្តរមានជ័យ ទទួលបានលទ្ធផលល្អប្រសើរ ដូចមានរាយនាមខាងក្រោម ៖

១-លោក ម៉ិច រតនា នាយករងរដ្ឋបាលសាលាខេត្ត
២-លោក សេង សុខកញ្ញារិទ្ធ នាយការិយាល័យមន្ទីរទំនាក់ទំនងសភា.ព្រឹទ្ធសភានិងអធិការកិច្ច
៣-លោក ហ៊ឹម បញ្ញា នាយការិយាល័យមន្ទីរទំនាក់ទំនងសភា.ព្រឹទ្ធសភានិងអធិការកិច្ច
៤-លោក គ្រាត់ សាខុន អាជីវករនៅខេត្តឧត្តរមានជ័យ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១០
នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១២១៧ . អនក្រ . បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ**តាមលំដាប់ថ្នាក់ចំនួន០៣គ្រឿងជូនអង្គការនិងអ្នកស្ម័គ្រចិត្តជប៉ុន ដែលបានជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បំពាក់សម្ភារៈគ្រប់គ្រាន់ បង្គន់អនាម័យ ០១ខ្នង មាន០៤បន្ទប់ និង ប្រព័ន្ធបង្ហូរទឹក នៅសាលាបឋមសិក្សាថារថ្មី ឃុំគោកបល្ល័ង្គ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ចំណាយអស់ទឹកប្រាក់សរុបចំនួន ៥៦.៤៧៨ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមាសស្ថាបនាជាតិ:

-អង្គការ ជេ អេច ភី (JHP)

ខ-មេដាយប្រាក់ស្ថាបនាជាតិ:

១-**អ្នកចូលរួមសន្សំប្រៃសណីយ៍ជប៉ុន សំរាប់ជំនួយស្ម័គ្រចិត្តអន្តរជាតិ** (All participants in Japan`s Postal Savings for International Voluntary Aid)

២-**អ៊ិនធើរីយើ ហ៊ីរ៉ាដេ** (INTERIOR HIRADE)

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ [illegible] ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១២១៣.អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០១គ្រឿង ជូន លោក MASAHIRO SANO ដែលជាឪពុកម្តាយធម៌របស់អង្គការអាស៊ីអេស្តេកា ចាប់តាំងពីឆ្នាំ ២០០០ មក ដែលបានជួយឧបត្ថម្ភគាំទ្រលើវិស័យសុខុមាលភាពកុមារ បានឧបត្ថម្ភទោចក្រយានជូនដល់កុមារក្រីក្រ ចំនួន ០៣លើក ហើយក្នុងមួយលើកជូនទោចក្រយាន ៤៦០គ្រឿង ដល់មណ្ឌលកុមារកំព្រាមួយចំនួនដូចជា ខេត្តកណ្តាល កំពង់ចាម ព្រះសីហនុ សៀមរាប និងខេត្តកំពត ថែមទាំងមានគម្រោងឧបត្ថម្ភ ដល់ខេត្តកំពង់ឆ្នាំងបន្តទៀត ដោយចំណាយទឹកប្រាក់សរុបទាំង ០៤លើក ចំនួន ២.៩៧២.៥០០ យេន និង ៣៦.៥៤០ ដុល្លារអាមេរិក។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១០

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួលៈ
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១២៧៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសុវត្ថារា

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយសុវត្ថារា ថ្នាក់ ធិបឌិន្ទ ចំនួន ០២គ្រឿង ជូនមន្ត្រីរាជការ ចំនួន ០២រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង សមិទ្ធផលនានា លើវិស័យព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅវត្តអារញ្ញគីរីគុកកំបោរ និងវត្តគីរីធម្មជោតិ ស្ថិតនៅក្នុងឃុំឫស្សីស្រុកខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត ដូចមានរាយនាមខាងក្រោម៖

១- វរសេនីយ៍ឯក អ៊ុំ ឈួន អត្តលេខ ០៣៧៤៤ ស្នងការរងនគរបាលខេត្តកំពត ថវិកា ៧០.០០០ ដុល្លារ
២- វរសេនីយ៍ត្រី គី ធឿន អត្តលេខ ១០៩៦៧ នាយការិយាល័យប្រឆាំងភេរវកម្ម ថវិកា ៦៨.៨០០ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាល ខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧១៥ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០៦ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន ១៨គ្រឿង ប្រគេន និងជូនសប្បុរសជន ចំនួន ១៨រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាង សមិទ្ធផលនានា លើវិស័យព្រះពុទ្ធសាសនា និងហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ នៅវត្តអារញ្ញគិរីគុកកំបោរ និងវត្តគិរីធម្មជោតិ ស្ថិតនៅក្នុងឃុំឫស្សីស្រុកខាងកើត ស្រុកកំពង់ត្រាច ខេត្តកំពត ដូចមានរាយព្រះនាម និងនាមខាងក្រោម៖

ក-មេដាយមាសស្ថាបនាជាតិៈ

១-	ព្រះតេជគុណ	ជិន ចាន់ត្ថារា	ព្រះចៅអធិការវត្តគិរីធម្មជោតិ	បច្ច័យ ១៥.១២០ ដុល្លារ
២-	អ្នកស្រី	តាំង មួយ	សប្បុរសជនខ្មែររស់នៅប្រទេសកាណាដា	ថវិកា ១០.៥១០ ដុល្លារ
៣-	ឧបាសិកា	ខន ញ៉េវ	សប្បុរសជននៅប្រទេសវៀតណាម	ថវិកា ១០.៣០២ ដុល្លារ
៤-	លោក	យង់ សាមឿន	មេឃុំឫស្សីស្រុកខាងកើត	ថវិកា ១០.២០០ ដុល្លារ
៥-	អ្នកស្រី	ហាន សៀវជាន	សប្បុរសជនខ្មែររស់នៅប្រទេសអូស្ត្រាលី	ថវិកា ១០.១៣០ ដុល្លារ
៦-	ឧបាសិកា	ធា គូរ	សប្បុរសជននៅប្រទេសវៀតណាម	ថវិកា ១០.១២៥ ដុល្លារ
៧-	លោក	យស់ សំណាង	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ១០.១០៥ ដុល្លារ
៨-	ឧបាសិកា	ជៀម សាមិត្ត	សប្បុរសជននៅខេត្តកំពង់ចាម	ថវិកា ១០.១០០ ដុល្លារ

៩-	ឧបាសិកា	លន ឃឹម	សប្បុរសជននៅខេត្តកណ្ដាល	ថវិកា ១០.០៧៣ ដុល្លារ
១០-	លោក	ញ៉ិក ម៉ា	សប្បុរសជននៅប្រទេសវៀតណាម	ថវិកា ១០.០៧២ ដុល្លារ
១១-	ឧបាសិកា	ផេង មួយ	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ១០.០០០ ដុល្លារ
១២-	ឧបាសក	មាស សុទ្ធ	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ១០.០០០ ដុល្លារ
១៣-	ឧបាសិកា	ឆេង តៃ	សប្បុរសជននៅរាជធានីភ្នំពេញ	ថវិកា ១០.០០០ ដុល្លារ
១៤-	លោក	ម៉ែម ច័ន្ទដារា	សប្បុរសជននៅខេត្តកំពត	ថវិកា ១០.០០០ ដុល្លារ
១៥-	អ្នកស្រី	អ៊ាង ដារិន	សប្បុរសជននៅខេត្តកំពត	ថវិកា ១០.០០០ ដុល្លារ

ខ-មេដាយប្រាក់ស្ថាបនាជាតិ:

១-	អ្នកស្រី	ថាង ខៀវ	សប្បុរសជននៅខេត្តកំពត	ថវិកា ៥.១០០ ដុល្លារ
២-	ឧបាសក	លាន យង	សប្បុរសជននៅខេត្តកំពត	ថវិកា ៥.០០០ ដុល្លារ
៣-	ឧបាសក	កង អែម	សប្បុរសជននៅខេត្តកំពត	ថវិកា ៥.០០០ ដុល្លារ

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលនៃគណៈអភិបាល ខេត្តកំពត ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល:
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០១០

នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១២១៦ . អនក្រ . បក

អនុក្រឹត្យ
ស្ដីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយមុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនសប្បុរសជន ចំនួន០៤រូប ដែលមានគុណបំណាច់ និងស្នាដៃល្អចំពោះជាតិមាតុភូមិ និងព្រះពុទ្ធសាសនា ដោយបានបរិច្ចាគធនធានផ្ទាល់ខ្លួនជួយកសាងសមិទ្ធផលនានា ដើម្បីទុកជាសម្បត្តិសាធារណៈ នៅវត្តច័ន្ទបុរីវង្ស ឃុំសំរោង ស្រុកពញាឮ ខេត្តកណ្ដាល ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ:

១-អ្នកស្រី កែវ មុំ
២-លោក ដួង ឡឿន

ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ:

១-លោក អៀម ស៊ីដាត
២-លោក គួយ ម៉េង

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និងអភិបាលនៃគណៈអភិបាលខេត្តកណ្ដាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ [illegible] ឆ្នាំ ២០១០
នាយករដ្ឋមន្ត្រី

សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល:
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៧១៧. អនក្រ. បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ មេបញ្ជាការកងទ័ពជើងគោក

សម្រេច

មាត្រា ១.-

ត្រូវបានបំពាក់ មេដាយសហមេត្រី តាមលំដាប់ថ្នាក់ ជូនមន្ត្រីថ្នាក់ដឹកនាំនិងយោធាខេត្តខាញ់ហ័រ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម ចំនួន១០រូប ដែលមានស្នាដៃល្អក្នុងកិច្ចសហប្រតិបត្តិការជួយកសាងអង្គភាពតំបន់ប្រតិបត្តិការសឹករងស្ទឹងត្រែង រួមមានអគារការិយាល័យ ចំនួន០២ខ្នង អគារគិលានដ្ឋាន ចំនួន០១ខ្នង សរុបទឹកប្រាក់អស់ចំនួន ៤.៨៥១ លានដុង ដូចមានរាយនាមខាងក្រោម ៖

ក-មេដាយ សហមេត្រី ថ្នាក់ ធិបឌិន្ទ:

